Climate Change

affects people from all walks of life

ការប្រែប្រួលការអាកាសធាតុ មានឥទ្ធិពលលើប្រជាជនគ្រប់រូប


ស្រូវត្រូវការទឹកភ្លៀង ហើយយើងត្រូវការទឹកភ្លៀង។ ប៉ុន្តែសព្វថ្ងៃទឹកភ្លៀង ពុំសូវធ្លាក់តាមពេលវេលាទៀងទាត់ដូចមុនទេ។
ខ្ញុំលែងមានថ្ងៃដែលខ្ញុំធ្លាប់ប្រមូលសារ៉ាយទន្លេជាមួយស្រីៗនៅក្នុងភូមិទៀតហើយ ដោយសារតែសារ៉ាយទន្លេវាបាត់បង់អស់ហើយ។
ថាម៉េច? អាកាសធាតុអាចធ្វើអោយមានការប្រែប្រួល?
ទឹកជំនន់ធ្ងន់ធ្ងរ ធ្វើអោយយើងមិនអាចរៀបចំដំណើរកំសាន្តទេសចរបែបធម្មជាតិ ដូចជាអុំទូក និងការដើរកាត់ព្រៃកំសាន្ត។
ពេលថ្មីៗនេះ ភ្ញៀវដែលធ្លាប់មកកំសាន្តបង់ថ្លៃសេវាកម្មជាក្រេឌីត។ ចុះឥឡូវ? គេទាំងអស់គ្នា ធ្លាក់ខ្លួនក្រ ក្នុងពេលនេះដែរ? អ៊ុះ!
ត្រូវពិនិត្យគោលនយោបាយរដ្ឋាភិបាលឡើងវិញ។
គួរអោយខ្មាស់អៀនណាស់ដែលចៅប្រុសខ្ញុំប្រហែលជាគ្មានសំណាងបានឃើញត្រីរាជទៀតទេ នៅពេលវាធំឡើង។
កំណើនកំពស់ទឹកសមុទ្រ និងធ្វើអោយទឹកទន្លេឡើងប្រៃ ហើយឥឡូវខ្ញុំពិបាកនឹងប្រើប្រាស់ទឹកនេះសំរាប់តំរូវការប្រចាំថ្ងៃ។
ឥឡូវនេះ កូនយើងភាគច្រើនចាកចេញពីភូមិទៅរកការងារនៅទីក្រុង។ ដោយសារទន្លេ ប្រែប្រួលខុសពីមុន ជីវភាពរស់នៅរបស់យើង ក៏ខុសពីមុនដែរ។
ការបាក់ដីច្រាំងទន្លេ ធ្វើអោយខូចខាតផ្ទះសំរាប់លំហែរកាយចុងសប្តាហ៍ដែលឪពុកខ្ញុំទិញអោយ ជាកាដូរ កាលពីឆ្នាំមុន។
បញ្ហាខ្វះទឹកនៅក្នុងប្រទេសខ្ញុំ ឥឡូវនេះ រីករាលដាលទៅជាបញ្ហាតំបន់ហើយ។
កង្វះខាតធនធានធម្មជាតិអាចបណ្តាលអោយមានទំនាស់រវាងប្រទេសនិងប្រទេស។

ការប្រែប្រួលអាកាសធាតុបង្ករផលវិបាកដល់ពិភពលោកទាំងមូល។ អ្នកប្រើរថយន្តនៅអឺរ៉ុប រួមចំណែកបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលនាំអោយកើនសីតុណ្ហភាព និងបង្ករអោយមានគ្រោះ រាំងស្ងួតនៅអាស៊ី។




INCREASING TEMPERATURE
កំណើនសីតុណ្ហភាព
FLOOD
គ្រោះទឹកជំនន់
DROUGHT
គ្រោះរាំងស្ងួត
RISING SEA LEVEL
កំណើនកំពស់ទឹកសមុទ្រ

ការសិក្សាបង្ហាញថា ការប្រែប្រួលអាកាសធាតុ នឹងផ្លាស់ប្តូររបបអាកាសធាតុនៅក្នុងតំបន់ទន្លេ មេគង្គក្រោម។ នៅឆ្នាំ ២០៣០ ផលវិបាកនៃការប្រែប្រួលអាកាសធាតុនឹងរួមមាន:

- សីតុណ្ហភាពមធ្យម នឹងកើន ០.៨ អង្សារថែមទៀត
- គ្រោះរាំងស្ងួត និងទឹកជំនន់ធ្ងន់ធ្ងរកាន់តែច្រើន នឹងប៉ះពាល់ដល់ផលិតផលកសិកម្ម និងជលផល។
- កំណើនកំពស់ទឹកសមុទ្រ នៅដីសណ្តទន្លេមេគង្គនៅប្រទេសវៀតណាមភាគខាងត្បូង។

MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT